# ភូមិ ៣១ ចែកជា ៣ ពួក



## ពួកទី ១ ពោលដោយលំដាប់ឋាន មាន ៣ គឺ ៖

**១. កាមភូមិ ១១** មាន **អបាយភូមិ ៤** (គឺ នរក ប្រេត តិរច្ឆាន អសុរកាយ) និង **កាមសុគតិភូមិ ៧** គឺ មនុស្ស ចាតុមហារាជិកា តាវត្តិង្ស យាមា តុសិត និម្មានរតី បរនិម្មិតវសវត្តី ។

**២. រូបភូមិ ១៦** មាន **បឋមជ្ឈានភូមិ ៣** (គឺព្រហ្មបារិសជ្ជា ព្រហ្មបុរោហិតា មហាព្រហ្មា) **ទុតិយជ្ឈានភូមិ ៣** (គឺបរិត្តាភា អប្បមាណាភា អាភស្សរា) **តតិយជ្ឈានភូមិ ៣** (គឺ បរិត្តសុភា អប្បមាណសុភា សុភកិណ្ហា) និង **ចតុត្ថជ្ឈានភូមិ ៧** (វេហប្ផលា អសញ្ញីសត្តា និង **សុទ្ធាវាសភូមិ ៥** គឺ អវិហា អតប្បា សុទស្សា សុទស្សី អកនិដ្ឋា) ។

**៣. អរូបភូមិ ៤** មាន អាកាសានញ្ចាយតភូមិ វិញ្ញាណញ្ចាយតនភូមិ អាកិញ្ចញ្ញាយតនភូមិ នេវសញ្ញានាសញ្ញាយតនភូមិ ។

## ពួកទី ២ ពោលដោយខន្ធ មាន ៣ គឺ ៖

**១. បញ្ចវោការភូមិ** ភូមិជាទីនៅនៃសត្វដែលមានខន្ធ ៥ មាន ២៦ គឺ កាមភូមិ ១១ រូបភូមិ ១៥ (វៀរអសញ្ញីសត្តា) ។

**២. ចតុវោការភូមិ** ភូមិជាទីនៅនៃសត្វដែលមានខន្ធ ៤ មាន ៤ គឺ អរូបភូមិ ។

**៣. ឯកវោការភូមិ** ភូមិជាទីនៅនៃសត្វដែលមានខន្ធ ១ មាន ១ គឺ អសញ្ញីសត្តា ។

## ពួកទី ៣ ពោលដោយសញ្ញា មាន៣ គឺ ៖

**១. សញ្ញីភូមិ** ភូមិជាទីនៅនៃសត្វដែលមានសញ្ញា មាន ២៩ គឺ កាមភូមិ ១១ រូបភូមិ ១៥ (វៀរអសញ្ញីសត្តា) និង អរូបភូមិ ៣ (វៀរនេវសញ្ញានាសញ្ញាយតនភូមិ)។

**២. អសញ្ញីភូមិ** ភូមិជាទីនៅនៃសត្វដែលមិនមានសញ្ញា មាន ១ គឺ អសញ្ញីសត្តាភូមិ ។

**៣. នេវសញ្ញីនាសញ្ញីភូមិ** ភូមិជាទីនៅនៃសត្វដែលមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន មាន១គឺនេវសញ្ញានាសញ្ញាយតនភូមិ ។